គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

# ផែនការសកម្មភាព
## ឆ្នាំ ២០២៥ - ២០២៨ របស់អគ្គលេខាធិការដ្ឋាន
## គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

មិថុនា ២០២៥

# មាតិកា


**បុព្វកថា** ............................................................ I

**អារម្ភកថា** ............................................................ III

**១. សេចក្ដីផ្ដើម** ............................................................ ៥

**២. គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់** ............................................................ ៦

២.១. ចក្ខុវិស័យ ............................................................ ៦

២.២. បេសកកម្ម ............................................................ ៦

២.៣. យុទ្ធសាស្ត្រ ............................................................ ៦

២.៤. តួនាទី និងភារកិច្ច ............................................................ ៧

២.៤.១. តួនាទី និងភារកិច្ចរបស់ គ.ក.ច. ............................................................ ៧

២.៤.២. តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន គ.ក.ច. ............................................................ ៨

២.៥. រចនាសម្ព័ន្ធ ............................................................ ១០

២.៦. ធនធានមនុស្ស ............................................................ ១១

២.៧. គោលដៅ ............................................................ ១១

២.៨. បទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងស្ថាប័ន ............................................................ ១២

**៣. សមិទ្ធផលការងារដែលបានអនុវត្តកន្លងមក** ............................................................ ១២

៣.១. ការងារក្របខ័ណ្ឌគោលនយោបាយ ............................................................ ១២

៣.២. ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ............................................................ ១៣

៣.៣. ការតាក់តែងគោលការណ៍ណែនាំស្ដីពីនីតិវិធី និងវិធាននៃការតាក់តែងសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ............................................................ ១៤

៣.៤. ការជ្រើសរើសអ្នកជំនាញការផ្នែកច្បាប់ ............................................................ ១៤

៣.៥. ការរៀបចំទីស្នាក់ការរបស់អគ្គលេខាធិការដ្ឋាន គ.ក.ច. ............................................................ ១៥

៣.៦. ការដឹកនាំ និងរៀបចំកិច្ចប្រជុំវឌ្ឍនភាពការងារ ............................................................ ១៦

៣.៧. កម្មវិធីផ្សេងៗ ............................................................ ១៧

៣.៨. ការងារផ្សេងៗទៀត ............................................................ ២០

៤. ផែនការសកម្មភាពឆ្នាំ ២០២៥ - ២០២៨ របស់អគ្គលេខាធិការដ្ឋាន គ.ក.ច. ..........២០
៥. លទ្ធផលរំពឹងទុករបស់អគ្គលេខាធិការដ្ឋាន គ.ក.ច. ..........២២
៦. ការតាមដាន និងត្រួតពិនិត្យលើការអនុវត្តផែនការសកម្មភាព..........២៣
៧. សេចក្តីសន្និដ្ឋាន..........២៤
ឧបសម្ព័ន្ធទី១. សម្គាល់អក្សរកាត់ក្នុងតារាងម៉ាទ្រីស..........២៦
ឧបសម្ព័ន្ធទី២. តារាងម៉ាទ្រីសផែនការសកម្មភាពឆ្នាំ ២០២៥ - ២០២៨..........២៧

# បុព្វកថា

កម្មវិធីជាតិកែទម្រង់ច្បាប់ ជាកម្មវិធីកែទម្រង់គន្លឹះមួយក្នុងចំណោមកម្មវិធីកែទម្រង់គន្លឹះទាំង ៥ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលរួមមាន ១. កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២. កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ៣. កម្មវិធីជាតិកែទម្រង់ច្បាប់ ៤. កម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ និង ៥. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ កម្មវិធីកែទម្រង់ទាំងនេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីជំរុញការកែទម្រង់និងការពង្រឹងអភិបាលកិច្ចដែលជាស្នូលនៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងនីតិកាលជាបន្តបន្ទាប់ ជាពិសេស យុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលនីតិកាលទី៧។ គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ (**គ.ក.ច.**) ត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យ លេខ នស/រកត០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ហើយក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ត្រូវបានដាក់ឱ្យអនុវត្តកាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៥ ដោយកំណត់នូវចក្ខុវិស័យក្នុងការកសាងនិម្មាបនកម្មនៃប្រព័ន្ធច្បាប់និងវប្បធម៌នីតិរដ្ឋ ដោយផ្អែកទៅលើគុណតម្លៃប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា និងគុណតម្លៃសាកល។ នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ (**អ.គ.ក.ច.**) ជាតួអង្គមួយដ៏សំខាន់ដែលជាដងខ្លួនរបស់ **គ.ក.ច.** ក្នុងការដឹកនាំរៀបចំនិងសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រគាំទ្រ ដោយផ្អែកលើកិច្ចការគន្លឹះចំនួន ៤ ដូចតទៅ៖

១. រៀបចំផែនការសកម្មភាពតាមដំណាក់កាលនីមួយៗ
២. រៀបចំស្តង់ដាប្រតិបត្តិការងារសម្រាប់យុទ្ធសាស្ត្រគន្លឹះទាំង៤
៣. រៀបចំប្រព័ន្ធឌីជីថលលូបនីយកម្មសម្រាប់យុទ្ធសាស្ត្រគន្លឹះទាំង៤
៤. រៀបចំផែនការអភិវឌ្ឍស្ថាប័នសម្រាប់ **គ.ក.ច.**។

លើសពីនេះទៀត អគ្គលេខាធិការដ្ឋាន **គ.ក.ច.** នឹងត្រូវរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពដោយឡែករបស់ខ្លួន ដើម្បីគាំទ្រដល់ការដឹកនាំនិងការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ **គ.ក.ច.**។ ដើម្បីអាចបំពេញតួនាទីដ៏សំខាន់នេះបាន អគ្គលេខាធិការដ្ឋាន **គ.ក.ច.** ត្រូវអភិវឌ្ឍខ្លួនជាមជ្ឈមណ្ឌលឧត្តមភាព (Center of Excellence) និងជាអង្គភាពដែលមានសមត្ថភាពនិងវិជ្ជាជីវៈខ្ពស់ ព្រមទាំងមានក្រមសីលធម៌ក្នុងការបំពេញការងារប្រកបដោយគុណភាព ប្រសិទ្ធភាព រួមទាំងនិរន្តរភាព ស្របតាមគុណតម្លៃស្នូលចំនួន ៤ រួមមាន៖ ១. នីតិរដ្ឋនិងការការពារផលប្រយោជន៍សាធារណៈ ២. គុណាធិបតេយ្យ ៣. សាមគ្គីភាពនិងបរិយាបន្ន ៤. វិជ្ជាជីវៈនិងក្រមសីលធម៌។

ផែនការសកម្មភាពឆ្នាំ ២០២៥ - ២០២៨ របស់អគ្គលេខាធិការដ្ឋាន **គ.ក.ច.** ជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការកសាងនិងអភិវឌ្ឍស្ថាប័ន ដើម្បីអភិបាលកិច្ចល្អក្នុងស្ថាប័ន និងជាត្រីវិស័យដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.** ទាំងអស់ក្នុងការបំពេញតួនាទី ភារកិច្ចរបស់ខ្លួនប្រកបដោយគុណភាព និងប្រសិទ្ធភាព។ ដើម្បីឱ្យផែនការសកម្មភាពនេះអាចសម្រេចបានតាមគោលដៅដែលបានគ្រោងទុក ខ្ញុំសូមលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.** និងតួអង្គពាក់ព័ន្ធទាំងអស់បំពេញការងារប្រកបដោយស្មារតីបុរេសកម្ម ការទទួលខុសត្រូវខ្ពស់ និងជវភាពនៃប្រព័ន្ធតួអង្គតែមួយ។

លើសពីនេះផងដែរ ខ្ញុំក៏សូមអំពាវនាវដល់ក្រសួង ស្ថាប័នទាំងអស់ចូលរួមក្នុងការផ្តល់កិច្ចសហការជាមួយអគ្គលេខាធិការដ្ឋាន **គ.ក.ច.** ក្នុងការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ផែនការសកម្មភាព និងជាពិសេសទៅទៀតនោះ ក្នុងការបង្កើតក្រុមការងារកែទម្រង់ច្បាប់នៅតាមក្រសួង ស្ថាប័ន ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់។

ជាទីបញ្ចប់ ខ្ញុំសូមកោតសរសើរដល់ក្រុមការងាររៀបចំផែនការសកម្មភាពឆ្នាំ ២០២៥ - ២០២៨ របស់អគ្គលេខាធិការដ្ឋាន **គ.ក.ច.** ដែលដឹកនាំដោយ **ឯកឧត្តម លី ច័ន្ទតុលា** អនុប្រធាននិងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.** និងប្រកាសដាក់ឱ្យអនុវត្តផែនការសកម្មភាពឆ្នាំ ២០២៥ - ២០២៨ របស់អគ្គលេខាធិការដ្ឋាន **គ.ក.ច.** ចាប់ពីពេលនេះតទៅ។

ថ្ងៃ ខែ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់**

**វង្សី វិស្សុត**

# អារម្ភកថា

តាមរយៈព្រះរាជក្រឹត្យលេខ នស/រកត០២២៤ /១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ (**គ.ក.ច.**) អនុក្រឹត្យលេខ១០៤ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ **អ.គ.ក.ច.** និងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៥ រាជរដ្ឋាភិបាលបានកំណត់នូវចក្ខុវិស័យ បេសកកម្ម និងយុទ្ធសាស្ត្រច្បាស់លាស់ក្នុងការកែទម្រង់ច្បាប់មួយដ៏ស៊ីជម្រៅនៅព្រះរាជាណាចក្រកម្ពុជា។ ជាមួយគ្នានេះផងដែរ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ វង្សី វិស្សុត រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាន គ.ក.ច.** បានផ្តល់ការយកចិត្តទុកដាក់ខ្ពស់ដោយផ្ទាល់ និងបានផ្តល់អនុសាសន៍ណែនាំ កំណត់គោលដៅ ត្រួសត្រាយផ្លូវ និងលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.** ទាំងអស់ ក្នុងបុព្វហេតុនៃការកសាងនិម្មាបនកម្មនៃប្រព័ន្ធច្បាប់ និងវប្បធម៌នីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកលើគុណតម្លៃប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា និងគុណតម្លៃសកល ជាពិសេសក្នុងដំណាក់កាលដំបូងនៃការកសាងនិងអភិវឌ្ឍស្ថាប័ន **គ.ក.ច.**។ ថ្វីត្បិតជាអង្គភាពក្មេងខ្ចី អគ្គលេខាធិការដ្ឋាន **គ.ក.ច.** ក្នុងនាមជាសេនាធិការរបស់ **គ.ក.ច.** បានខិតខំប្រឹងប្រែងបំពេញតួនាទី និងគុណតម្លៃរបស់ខ្លួនប្រកបដោយស្មារតីបុរេសកម្ម ការទទួលខុសត្រូវខ្ពស់ និងជវភាពនៃប្រព័ន្ធតួអង្គតែមួយ។ ជាក់ស្តែង តាមរយៈផែនការសកម្មភាពឆ្នាំ ២០២៥ - ២០២៨ អគ្គលេខាធិការដ្ឋាន **គ.ក.ច.** ខិតខំប្រឹងប្រែងកសាងនិងអភិវឌ្ឍខ្លួនឱ្យក្លាយជាមជ្ឈមណ្ឌលឧត្តមភាពមួយ ដែលមានសមត្ថភាពនិងវិជ្ជាជីវៈខ្ពស់ និងមានក្រមសីលធម៌ក្នុងការបំពេញការងារ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងនិរន្តរភាព ដោយដាក់ចេញនូវគោលដៅជាយុទ្ធសាស្ត្រចំនួន ៦ ដូចខាងក្រោម៖

គោលដៅទី១៖ កសាងនិងអភិវឌ្ឍស្ថាប័ននិងធនធានមនុស្ស

គោលដៅទី២៖ កសាងកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ

គោលដៅទី៣៖ ដឹកនាំនិងសម្របសម្រួលចងក្រងនិងផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

គោលដៅទី៤៖ ដឹកនាំនិងសម្របសម្រួលរៀបចំក្របខ័ណ្ឌតាក់តែងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

គោលដៅទី៥៖ ដឹកនាំសម្របសម្រួលនិងពិនិត្យវាយតម្លៃគុណភាពនិងប្រសិទ្ធភាពនៃការតាក់តែងនិងអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

គោលដៅទី៦៖ ដឹកនាំនិងសម្របសម្រួលរៀបចំក្របខ័ណ្ឌដោះស្រាយវិវាទគតិយុត្ត និងការពារនីត្យានុកូលភាព។

ក្នុងនាមជាអង្គភាពដឹកនាំការអនុវត្តយុទ្ធសាស្ត្រគាំទ្រដល់ការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រនៃ

កម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល អគ្គលេខាធិការដ្ឋាន **គ.ក.ច**. ប្តេជ្ញាខិតខំបំពេញតួនាទីរបស់ខ្លួន និងអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ផែនការសកម្មភាព និងអនុសាសន៍របស់ថ្នាក់ដឹកនាំ ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនឹងនេះ ខ្ញុំក៏សូម **គ.ក.ច**. និងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ មេត្តាផ្តល់កិច្ចសហការ និងគាំទ្រដល់អគ្គលេខាធិការដ្ឋាន **គ.ក.ច**. ដើម្បីសម្រេចបានដោយជោគជ័យនូវបេក្ខវិស័យក្នុងការកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល។

ថ្ងៃ ខែ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៥

**អនុប្រធាននិងជាអគ្គលេខាធិការ**

**គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់**

**លី ច័ន្ទតុលា**

# ផែនការសកម្មភាព ឆ្នាំ ២០២៥ - ២០២៨
# របស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

## ១. សេចក្តីផ្តើម

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ (**គ.ក.ច.**) ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ដើម្បីជាយន្តការដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តការងារកែទម្រង់ច្បាប់ ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងគោលបំណងពង្រឹងនិងលើកកម្ពស់គោលការណ៍នីតិរដ្ឋ សន្តិសុខគតិយុត្ត ព្រមទាំងគុណភាពនិងប្រសិទ្ធភាពនៃច្បាប់។ ជាមួយគ្នានេះ **គ.ក.ច.** ត្រូវបំពេញតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួល គាំទ្រ និងពង្រឹងមុខងារនីតិកម្មនៃក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល ជាមួយនឹងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងបុព្វហេតុនៃការពង្រឹងនិងពង្រីកគុណភាព ប្រសិទ្ធភាព នៃវប្បធម៌នីតិរដ្ឋរបស់ព្រះរាជាណាចក្រកម្ពុជា និងមានវិសាលភាពគ្របដណ្តប់ លើការកសាងប្រព័ន្ធច្បាប់កម្ពុជាទាំងមូលនៅលើមាគ៌ានៃការពង្រឹងអភិបាលកិច្ច និងធានាចីរភាពនៃវប្បធម៌នីតិរដ្ឋ ស្របតាមឧត្តមានុវត្តន៍អន្តរជាតិផង និងបរិការណ៍ប្រវត្តិសាស្ត្រកម្ពុជាផង។

ចាប់តាំងពីពេលបង្កើត និងទទួលបានអាណត្តិរបស់ខ្លួនក្នុងការបំពេញការងារ **គ.ក.ច.** បានកំណត់ការងារចំពោះមុខដែលបានអនុវត្ត ដែលរួមមានការងារក្របខ័ណ្ឌគោលនយោបាយ តាក់តែងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល តាក់តែងគោលការណ៍ណែនាំស្តីពីនីតិវិធី និងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ការជ្រើសរើសអ្នកជំនាញការផ្នែកច្បាប់ ការរៀបចំទីស្នាក់ការបណ្តោះអាសន្នរបស់ អគ្គលេខាធិការដ្ឋាន **គ.ក.ច.** និងការងារផ្សេងៗទៀតដែលបាននឹងកំពុងរៀបចំ។ ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋាន **គ.ក.ច.** បានខិតខំបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនស្របតាមបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងស្ថាប័ន ក៏ដូចជាបានកំណត់នូវបញ្ហាប្រឈមមួយចំនួនដូចជា កង្វះខាតប្រព័ន្ធបច្ចេកវិទ្យា កង្វះខាតមន្ត្រីបម្រើការងារនៅនាយកដ្ឋានទាំង ៤ នៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.** និងកង្វះខាតយុទ្ធសាស្ត្រ និងឧត្តមានុវត្ត សម្រាប់តាក់តែងរៀបចំផែនការប្រតិបត្តិក្នុងការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ច្បាប់របស់ រាជរដ្ឋាភិបាល និងក្របខ័ណ្ឌទស្សនាទាននានា។

អគ្គលេខាធិការដ្ឋាន **គ.ក.ច.** បានដាក់ចេញនូវផែនការសកម្មភាពឆ្នាំ ២០២៥ - ២០២៨ ដោយមានការងារចំនួន ៣១ កម្មវិធី និង ១៦២ សកម្មភាព ដែលក្នុងនោះត្រូវបានបែងចែកតាមគោលដៅធំៗចំនួន ៦ ក្នុងនោះរួមមាន គោលដៅទី១៖ កសាងនិងអភិវឌ្ឍស្ថាប័ន និងធនធានមនុស្សមានចំនួន ៨ កម្មវិធី និង ៦៩ សកម្មភាព គោលដៅទី២៖ កសាងកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ

មានចំនួន ២ កម្មវិធី និង ១០ សកម្មភាព គោលដៅទី៣៖ ដឹកនាំនិងសម្របសម្រួលការចងក្រង និងផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត មានចំនួន ៨ កម្មវិធី និង ៣២ សកម្មភាព គោលដៅទី៤៖ ដឹកនាំនិងសម្របសម្រួលរៀបចំក្របខ័ណ្ឌតាក់តែងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត មានចំនួន ៥ កម្មវិធី និង ១៩ សកម្មភាព គោលដៅទី៥៖ ដឹកនាំនិងសម្របសម្រួលពិនិត្យនិងវាយតម្លៃគុណភាព និងប្រសិទ្ធភាពនៃការតាក់តែង និងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត មានចំនួន ៤ កម្មវិធី និង ១៦ សកម្មភាព និង គោលដៅទី៦៖ ដឹកនាំ និងសម្របសម្រួលរៀបចំក្របខ័ណ្ឌដោះស្រាយវិវាទគតិយុត្ត និងការពារនីត្យានុកូលភាព មានចំនួន ៤ កម្មវិធី និង ១៦ សកម្មភាព។

## ២. គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

### ២.១. ចក្ខុវិស័យ

ដើម្បីជានាស្ថិរភាព និងចីរភាពនៃការកសាងរដ្ឋមួយដែលរឹងមាំ ឯករាជ្យ អធិបតេយ្យ ប្រជាធិបតេយ្យសេរីពហុបក្ស គោរពសិទ្ធិ សេរីភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស សមធម៌និងយុត្តិធម៌ក្នុងសង្គម វប្បធម៌ចុំថ្កើងរុងរឿង និងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារជឿនលឿន សុខុមាលភាពពលរដ្ឋ នាយុគសម័យបច្ចេកវិទ្យាទំនើប **គ.ក.ច**. បានកំណត់ចក្ខុវិស័យរបស់ខ្លួន "**ជានិម្មាបនករនៃប្រព័ន្ធច្បាប់ និងវប្បធម៌នីតិរដ្ឋដោយផ្អែកលើគុណតម្លៃប្រវត្តិសាស្ត្ររបស់កម្ពុជា និងគុណតម្លៃសាកល**"។

### ២.២. បេសកកម្ម

**គ.ក.ច**. មានបេសកកម្មដឹកនាំ និងសម្របសម្រួលការកែទម្រង់ច្បាប់កម្ពុជា ឱ្យទៅជាប្រព័ន្ធច្បាប់មួយដែលមានឯកភាព ប្រសិទ្ធភាព សមានគតិភាព ឧត្តមានុភាពគតិយុត្ត និងសន្តិសុខគតិយុត្ត ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ និងបរិការណ៍កម្ពុជា។

### ២.៣. យុទ្ធសាស្ត្រ

ដើម្បីសម្រេចបានចក្ខុវិស័យ និងបេសកកម្មខាងលើ យុទ្ធសាស្ត្រគន្លឹះ ៤ ខាងក្រោមត្រូវបានដាក់ឱ្យអនុវត្ត៖

១. ដឹកនាំនិងសម្របសម្រួលចងក្រង និងផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

២. ដឹកនាំនិងសម្របសម្រួលរៀបចំក្របខ័ណ្ឌតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

៣. ដឹកនាំនិងសម្របសម្រួលពិនិត្យ និងវាយតម្លៃគុណភាព និងប្រសិទ្ធភាពនៃការតាក់តែង និងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

៤. ដឹកនាំនិងសម្របសម្រួលរៀបចំក្របខ័ណ្ឌដោះស្រាយវិវាទគតិយុត្តនិងការពារនីត្យានុកូលភាព។

យុទ្ធសាស្ត្រគន្លឹះទាំង៤ ខាងលើនេះ ត្រូវអនុវត្តស្របតាមដំណាក់កាលចំនួន ៤ ដែលត្រូវអនុវត្តដំណាលគ្នានិង/ឬបន្តបន្ទាប់គ្នា ដូចតទៅ៖

១. **ពិនិត្យានុភាពរូបនីយកម្មគតិយុត្ត** សំដៅដល់ការផ្សព្វផ្សាយជាសាធារណៈ តាមបែបប្រពៃណីផង (លិខិតរឹង) និងបែបទំនើប ឬឌីជីថល (លិខិតទន់) ដែលជានាភាពជឿទុកចិត្តបាន សុពលភាពគតិយុត្ត អាចជំទាស់បាន និងទទួលស្គាល់ ឬទទួលខុសត្រូវដោយស្ថាប័នដាក់លាក់ (ដាក់ស្តែង ទីស្តីការគណៈរដ្ឋមន្ត្រី)

២. **សុខដុមភាវូបនីយកម្មគតិយុត្ត** សំដៅដល់ការធានាសង្គតិភាព បូរណភាព និងនីត្យានុកូលភាពនៃការតាក់តែងសេចក្តីព្រាងច្បាប់ ការបកស្រាយ និងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

៣. **ឯកសណ្ឋានរូបនីយកម្មនៃប្រព័ន្ធច្បាប់** សំដៅដល់ការបន្សុីគ្នារវាងប្រព័ន្ធច្បាប់កម្ពុជាបច្ចុប្បន្នជាមួយ នឹងប្រព័ន្ធច្បាប់ថ្មីៗ ស្របតាមតម្រូវការកែទម្រង់នានារបស់ក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាលក្នុងបំណងធានាឯកភាពជាប្រព័ន្ធនៃនីតិរដ្ឋកម្ពុជា

៤. **បូរណភាពនៃប្រព័ន្ធច្បាប់ និងចីរភាពនៃវប្បធម៌នីតិរដ្ឋ** សំដៅដល់ការកសាងអត្តសញ្ញាណនៃប្រព័ន្ធច្បាប់កម្ពុជា ដោយធានាបាននូវការប្រកាន់ខ្ជាប់ជានិរន្តរ៍នូវការគោរព ប្រតិបត្តិ និងតម្កល់ច្បាប់ជាធំ ពីសំណាក់ប្រជាពលរដ្ឋ អ្នកដឹកនាំ និងគ្រប់ក្រសួង ស្ថាប័ន ដោយស្មើភាពគ្នា និងជំនឿទុកចិត្ត។

## ២.៤. តួនាទី និងភារកិច្ច

### ២.៤.១. តួនាទី និងភារកិច្ចរបស់ គ.ក.ច.

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ (**គ.ក.ច.**) មានតួនាទីជាសេនាធិការរបស់រាជរដ្ឋាភិបាលនិងមានភារកិច្ចដូចខាងក្រោម ៖

- ដឹកនាំ គាំទ្រ សម្របសម្រួល និងជំរុញការអនុវត្តការងារការកែទម្រង់ច្បាប់
- ផ្តួចផ្តើមនិងលើកសំណើជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីពិនិត្យនិងសម្រេចលើផែនការយុទ្ធសាស្ត្រ នឹងផែនការសកម្មភាពកែទម្រង់ច្បាប់ ផ្អែកលើគោលនយោបាយរបស់រាជរដ្ឋាភិបាល
- លើកសំណើជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេចលើប្រព័ន្ធលើកទឹកចិត្តសម្រាប់គាំទ្រដល់ការអនុវត្តការងារកែទម្រង់ច្បាប់ ប្រកបដោយគុណភាព សង្គតិភាព និងប្រសិទ្ធភាព
- រៀបចំគោលការណ៍ណែនាំដើម្បីពង្រឹងគុណភាពនិងប្រសិទ្ធភាព ក្នុងការតាក់តែងនិងផ្តល់យោបល់លើការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត សំដៅធានាបាននូវ

ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព សង្គតិភាព និងភាពសមស្របតាមការវិវត្តនៃសេដ្ឋកិច្ច សង្គម និងដាក់ចេញ សេចក្តីណែនាំនិងវិធានការចាំបាច់នានា សំដៅធានាប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការងារកែទម្រង់ច្បាប់

- ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពពាក់ព័ន្ធនឹងការងារកែទម្រង់ច្បាប់
- សម្របសម្រួលនិងសហការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិនានា ដើម្បីជំរុញនិងគាំទ្រដល់ការអនុវត្តការងារកែទម្រង់ច្បាប់
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៅតាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល
- ផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តតាមគ្រប់មធ្យោបាយ
- ផ្សព្វផ្សាយព័ត៌មានស្តីពីសកម្មភាពនិងសមិទ្ធផលនានានៃការកែទម្រង់ច្បាប់
- ធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃការងារកែទម្រង់ច្បាប់ និងលើកសំណើវិធានការចាំបាច់នានា ដើម្បីដោះស្រាយបញ្ហាប្រឈមជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

### ២.៤.២. តួនាទី និងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន គ.ក.ច.

អគ្គលេខាធិការដ្ឋាន **គ.ក.ច.** មានតួនាទីជាសេនាធិការឱ្យ **គ.ក.ច.** និងមានភារកិច្ចមួយចំនួន ដែលត្រូវបំពេញដូចតទៅ៖

- សិក្សា ស្រាវជ្រាវ និងរៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព សម្រាប់ការងារកែទម្រង់ច្បាប់ កម្មវិធីសកម្មភាពសម្រាប់អនុវត្ត បញ្ជីបច្ចុប្បន្នកម្មនៃកម្មវិធីកសាង ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត និងសូចនាករសមិទ្ធកម្មគន្លឹះសម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តផែនការសកម្មភាពកែទម្រង់ច្បាប់ ដើម្បីដាក់ជូន **គ.ក.ច.** ពិនិត្យនិងសម្រេច
- កំណត់អាទិភាពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលលែងឆ្លើយតបនឹងវឌ្ឍនភាព សេដ្ឋកិច្ចសង្គម ដើម្បីធ្វើវិសោធនកម្ម ឬកែសម្រួល ឬរៀបចំថ្មី
- រៀបចំយន្តការជូន **គ.ក.ច.** ក្នុងការត្រួតពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតនៅតាមក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ

- សិក្សានិងប្រឹក្សាលើតម្រូវការនៃការរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីគាំទ្រដល់គោលនយោបាយនិងច្បាប់នានា
- ផ្តល់ការប្រឹក្សាលើអនុលោមភាព សន្តិសុខគតិយុត្ត សង្គតិភាព ចីរភាព និងសាមញ្ញភាពនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត
- ផ្តល់យោបល់ និងលើកសំណើដំណោះស្រាយជូន **គ.ក.ច.** លើបញ្ហាប្រឈមនឹងបញ្ហាបច្ចេកទេសនានាដើម្បីជំរុញ និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តការងារកែទម្រង់ច្បាប់
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃអំពីការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពកែទម្រង់ច្បាប់
- លើកសំណើអំពីដំណោះស្រាយដើម្បីកែលម្អច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលអាចនិរាករណ៍ ឬធ្វើវិសោធនកម្ម និងដំណោះស្រាយវិវាទនៃការបកស្រាយច្បាប់ដើម្បីធានាសន្តិសុខ គតិយុត្ត និងសុខដុមនីយកម្មគតិយុត្ត
- សហការ សម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និងអង្គការជាតិនិងអន្តរជាតិ និងផ្តល់ការគាំទ្រនិងជំនួយបច្ចេកទេសតាមការចាំបាច់ដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពនានាពាក់ព័ន្ធនឹងការរៀបចំនិងការអនុវត្តផែនការសកម្មភាពកែទម្រង់ច្បាប់ តាមការសម្រេចរបស់ **គ.ក.ច.**
- សម្របសម្រួលការងារជាមួយអង្គភាពដែលពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់នានារបស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- រៀបចំបទដ្ឋានឬស្តង់ដានីតិវិធីប្រតិបត្តិសម្រាប់ក្រសួង ស្ថាប័ន ក្នុងការតាមដាន ត្រួតពិនិត្យវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ដាក់ជូន **គ.ក.ច.** ពិនិត្យនិងសម្រេច
- រៀបចំប្រព័ន្ធឌីជីថលលូបនីយកម្ម និងរៀបចំ ចងក្រង បោះពុម្ពផ្សាយ និងផ្សព្វផ្សាយកម្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព័ត៌មាន សកម្មភាព និងសមិទ្ធផលនៃការងារកែទម្រង់ច្បាប់
- សម្របសម្រួល និងទទួលបន្ទុកការងាររដ្ឋបាលទូទៅប្រចាំថ្ងៃរបស់ **គ.ក.ច.**
- គ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ លទ្ធកម្មសាធារណៈ ទ្រព្យសម្បត្តិរដ្ឋ និងការងារបច្ចេកទេសរបស់អគ្គលេខាធិការដ្ឋាន **គ.ក.ច.**

- រៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់គាំទ្រដំណើរការងារ របស់ **គ.ក.ច.** និងរបស់អគ្គលេខាធិការដ្ឋាន **គ.ក.ច.** និងគាំទ្រដល់ការអនុវត្តការងារកែទម្រង់ច្បាប់
- រៀបចំសេចក្តីព្រាងប្រព័ន្ធលើកទឹកចិត្តប្រកបដោយសង្គតិភាព សមធម៌ ប្រសិទ្ធភាព និងចីរភាពក្នុងការអនុវត្តការកែទម្រង់ច្បាប់
- លើកគម្រោងការងារបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្ស
- រៀបចំរបាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តការងារកែទម្រង់ច្បាប់ និងរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ **គ.ក.ច.**
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធាន **គ.ក.ច.**។

## ២.៥. រចនាសម្ព័ន្ធ

អនុលោមតាមព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ អនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់ របស់រាជរដ្ឋាភិបាល បានកំណត់រចនាសម្ព័ន្ធរបស់ **គ.ក.ច.** និងអគ្គលេខាធិការដ្ឋាន **គ.ក.ច.**។ រចនាសម្ព័នរបស់ **គ.ក.ច.** ត្រូវបានបែងចែកជា ១. អគ្គលេខាធិការដ្ឋាន ២. គណៈកម្មការជំនាញ ៣. យន្តការស្ថាប័នអន្តរវិស័យ ៤. ក្រុមការងារកែទម្រង់ច្បាប់នៅក្នុងក្រសួង ស្ថាប័ន។

១. អគ្គលេខាធិការដ្ឋាន **គ.ក.ច.** មាននាយកដ្ឋានចំនួន ៤ គឺ៖

- នាយកដ្ឋានគោលនយោបាយ និងផែនការ
- នាយកដ្ឋានប្រឹក្សាច្បាប់ និងតាមដានការអនុវត្តច្បាប់
- នាយកដ្ឋានផ្សព្វផ្សាយ ទំនាក់ទំនងសាធារណៈ និងកិច្ចសហប្រតិបត្តិការ
- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច

២. គណៈកម្មការជំនាញទទួលបន្ទុកតាមវិស័យមានចំនួន ៤ គឺ៖

- គណៈកម្មការទទួលបន្ទុកវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងបច្ចេកវិទ្យា
- គណៈកម្មការទទួលបន្ទុកវិស័យសង្គមកិច្ច វប្បធម៌ និងបរិស្ថាន
- គណៈកម្មការទទួលបន្ទុកវិស័យរដ្ឋបាលសាធារណៈ និងនីតិអន្តរជាតិ
- គណៈកម្មការវិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការពារជាតិ។

៣. យន្តការស្ថាប័នអន្តរវិស័យមានចំនួន ២ គឺ៖

- គណៈកម្មការជាតិការពារនីត្យានុកូលភាព
- គណៈកម្មការជាតិភាសាច្បាប់

៤. ក្រុមការងារកែទម្រង់ច្បាប់នៅក្នុងក្រសួង ស្ថាប័ន។

## ២.៦. ធនធានមនុស្ស

**គ.ក.ច.** និង អគ្គលេខាធិការដ្ឋាន **គ.ក.ច.** មានសមាភាពសរុបចំនួនប្រមាណ ៤៩រូប ដោយក្នុងនោះរួមមាន **គ.ក.ច.** មានសមាជិកសរុបចំនួន ៣៤រូប (ប្រធាន ១រូប អនុប្រធានប្រចាំការ ១រូប អនុប្រធាន ៣រូប និងសមាជិក ២៩រូប) រីឯ អគ្គលេខាធិការដ្ឋាន **គ.ក.ច.** មានថ្នាក់ដឹកនាំ និងមន្ត្រីសរុបចំនួន ១៦រូប ក្នុងនោះមានអគ្គលេខាធិការ ១រូប អគ្គលេខាធិការរង ២រូប ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច ១រូប អនុប្រធាននាយកដ្ឋានគោលនយោបាយ និងផែនការ ១រូប និងអ្នកជំនាញការច្បាប់ចំនួន ១២រូប (គិតត្រឹមខែមិថុនា ឆ្នាំ២០២៥) ដោយឡែកមន្ត្រីនៅតាមនាយកដ្ឋានពុំទាន់បានជ្រើសរើសនៅឡើយ។

## ២.៧. គោលដៅ

អនុលោមតាមព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ អនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់ របស់រាជរដ្ឋាភិបាល។ អគ្គលេខាធិការដ្ឋាន **គ.ក.ច.** បានកំណត់គោលដៅសកម្មភាពចំនួន ៦ ដូចខាងក្រោម៖

គោលដៅទី១៖ កសាងនិងអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស

គោលដៅទី២៖ កសាងដៃគូសហប្រតិបត្តិការជាតិ និងអន្តរជាតិ

គោលដៅទី៣៖ ដឹកនាំនិងសម្របសម្រួលចងក្រងនិងផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

គោលដៅទី៤៖ ដឹកនាំនិងសម្របសម្រួលរៀបចំក្របខ័ណ្ឌតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

គោលដៅទី៥៖ ដឹកនាំនិងសម្របសម្រួលពិនិត្យនិងវាយតម្លៃគុណភាព និងប្រសិទ្ធភាពនៃការតាក់តែង និងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

គោលដៅទី៦៖ ដឹកនាំនិងសម្របសម្រួលរៀបចំក្របខ័ណ្ឌដោះស្រាយវិវាទគតិយុត្តនិងការពារនីត្យានុកូលភាព។

### ២.៨. បទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងស្ថាប័ន

កម្មវិធីជាតិកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ការតែងតាំងមុខតំណែង ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ដោយមានលិខិតបទដ្ឋានគតិយុត្តដូចខាងក្រោម៖

- ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
- សេចក្តីសម្រេចលេខ៥៦ សសរ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
- អនុក្រឹត្យលេខ ១០៤ អនក្រ.បក ចុះថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
- សេចក្តីសម្រេចលេខ១៧៣ សសរ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
- ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៦៤០ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៤ ស្តីពីការតែងតាំងមុខតំណែងនិងផ្តល់ឋានៈថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
- ព្រះរាជក្រឹត្យលេខ នស/រកត/០៣២៥/៣៩៨ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៥ ស្តីពីការតែងតាំងមុខតំណែង និងផ្តល់ឋានៈ ឯកឧត្តម សោម គន្ធា ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ មានឋានៈស្មើ រដ្ឋលេខាធិការ

## ៣. សមិទ្ធផលការងារដែលបានអនុវត្តកន្លងមក

**គ.ក.ច**. និង អគ្គលេខាធិការដ្ឋាន **គ.ក.ច**. បានកំពុងដំណើរការ និងអនុវត្តកម្មវិធីកែទម្រង់ច្បាប់ និងទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ដូចខាងក្រោម៖

### ៣.១. ការងារក្របខ័ណ្ឌគោលនយោបាយ

បន្ទាប់ពី រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា បានពិនិត្យឃើញអំពីវិសាលភាព សារៈសំខាន់ និងភាពចាំបាច់នៃការជំរុញល្បឿននៃការកែទម្រង់ច្បាប់ រាជរដ្ឋាភិបាលបានសម្រេចធ្វើវិចារណកម្មស្ថាប័ន នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដោយបង្កើតស្ថាប័នពីរដាច់ពីគ្នា ពោលគឺគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ដឹកនាំដោយទីស្តីការគណៈរដ្ឋមន្ត្រី តាមព្រះ

រាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធាន គ.ក.ច.** បានដឹកនាំ និងដាក់ចេញនូវទិសដៅច្បាស់លាស់ក្នុងការដឹកនាំ សម្របសម្រួល ការផ្តល់ប្រឹក្សា ការតាក់តែង ការត្រួតពិនិត្យ ការអនុវត្ត និងការដោះស្រាយវិវាទនៃច្បាប់ ដោយត្រូវជានាប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តច្បាប់។ កម្ពុជាត្រូវការប្រព័ន្ធច្បាប់មួយដែលផ្អែកលើនីតិរដ្ឋ ដើម្បីការពារឯករាជ្យ បូរណភាពទឹកដី ភាពជាម្ចាស់ ការពារសិទ្ធិមនុស្ស និងកម្មសិទ្ធិឯកជន យុត្តិធម៌សង្គម ព្រមទាំងគាំទ្រដល់សេដ្ឋកិច្ចទីផ្សារដែលរស់រវើក ក៏ដូចជាការអភិវឌ្ឍសង្គមសេដ្ឋកិច្ចទាំងមូល។

## ៣.២. ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ** បានរៀបចំកិច្ចប្រជុំ និងបង្កើតក្រុមការងារដើម្បីរៀបចំសេចក្តីព្រាងក្របខ័ណ្ឌយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល។ សេចក្តីព្រាងក្របខ័ណ្ឌយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាលនេះ ត្រូវបានរៀបចំឡើងដោយយកចិត្តទុកដាក់ និងពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយពីគ្រប់តួអង្គ និងភាគីពាក់ព័ន្ធទាំងអស់ សម្រាប់ជាមគ្គុទេសក៍បង្ហាញផ្លូវ សម្រាប់ដឹកនាំ សម្របសម្រួល និងជំរុញអនុវត្តការងារកែទម្រង់ច្បាប់ឱ្យទៅជាប្រព័ន្ធច្បាប់មួយដែលមានឯកភាព ប្រសិទ្ធភាព សមានគតិភាព ឧត្តមានុភាពគតិយុត្តិ និងសន្តិសុខគតិយុត្ត ស្របតាមឧត្តមានុវត្តន៍ អន្តរជាតិ និងបរិការណ៍កម្ពុជា។

សេចក្តីព្រាងក្របខ័ណ្ឌយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ត្រូវបានរៀបចំ និងដាក់ឆ្លងកិច្ចប្រជុំក្នុងក្របខ័ណ្ឌ **គ.ក.ច.** នាថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២៤ និងដាក់ពិភាក្សាយ៉ាងទូលំទូលាយក្នុងសិក្ខាសាលាថ្នាក់ជាតិ នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ ដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័នវិជ្ជាជីវៈច្បាប់ សាស្ត្រាចារ្យនីតិសាស្ត្រ អ្នកជំនាញការជាតិ និងអន្តរជាតិប្រមាណ ២៥០រូប។

បន្ទាប់ពីសិក្ខាសាលាខាងលើ អគ្គលេខាធិការដ្ឋាន **គ.ក.ច.** បានរៀបចំកិច្ចប្រជុំផ្ទៃក្នុងចំនួន១០លើក ដើម្បីបញ្ចូលធាតុចូលដែលទទួលបានពីសិក្ខាសាលា និងកែសម្រួលបញ្ចប់សេចក្តីព្រាងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាលនេះ។ ជាលទ្ធផល **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចចុះហត្ថលេខាលើក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៥។

## ៣.៣. ការតាក់តែងគោលការណ៍ណែនាំស្តីពីនីតិវិធី និងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត

គោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ និងត្រូវបានប្រកាសឱ្យប្រើតាមអនុក្រឹត្យលេខ១៧០ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ ២០២៤ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធី និងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។ គោលការណ៍ណែនាំនេះ ត្រូវបានរៀបចំឡើងដោយឈរលើទស្សនវិជ្ជានីតិរដ្ឋ (Rule of Law) ដែលរដ្ឋនីមួយៗត្រូវតែមានក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់និងគ្រប់ជ្រុងជ្រោយ ដែលធានាបាននូវសិទ្ធិ សេរីភាព កម្មសិទ្ធិឯកជននិងសាធារណៈ ការពារបាននូវតម្លៃនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស សមភាពចំពោះមុខច្បាប់ ធ្វើឱ្យការគ្រប់គ្រងវិស័យសេដ្ឋកិច្ច សង្គមកិច្ច ឧស្សាហកម្ម ពាណិជ្ជកម្ម កសិកម្ម និងទេសចរណ៍ ប្រព្រឹត្តទៅដោយរលូននិងមានប្រសិទ្ធភាព។ លើសពីនេះទៅទៀត រដ្ឋនីមួយៗត្រូវរៀបចំឱ្យមានប្រព័ន្ធនៃការតាមដាននិងត្រួតពិនិត្យការអនុវត្តច្បាប់ឱ្យបានហ្មត់ចត់ ដើម្បីធានាឱ្យមានយុត្តិធម៌ក្នុងសង្គម។ ក្នុងន័យនេះ ការរៀបចំតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានាដែលបម្រើឱ្យនីតិរដ្ឋ ត្រូវឈរលើគោលការណ៍ណែនាំមួយដែលក្រសួង ស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាលត្រូវយកទៅអនុវត្ត ដើម្បីធានាថា ច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងនោះមានគុណភាព សង្គតិភាព អនុលោមភាព សាមញ្ញភាព ចីរភាព សន្តិសុខគតិយុត្ត និងប្រសិទ្ធភាព។

## ៣.៤. ការជ្រើសរើសអ្នកជំនាញការផ្នែកច្បាប់

យោងតាមសេចក្តីសម្រេចលេខ០៧ សសរ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការបង្កើតគណៈកម្មការ និងអនុគណៈកម្មការប្រឡងជ្រើសរើសបេក្ខជនឱ្យចូលបម្រើការងារជំនាញការផ្នែកច្បាប់។ អគ្គលេខាធិការដ្ឋាន **គ.ក.ច.** បានរៀបចំគោលការណ៍ស្នើសុំជ្រើសរើស និងធ្វើសេចក្តីជូនដំណឹងជ្រើសរើសមន្ត្រីជំនាញការផ្នែកច្បាប់ ដោយនីតិវិធីនៃការជ្រើសរើសត្រូវបានរៀបចំយ៉ាងហ្មត់ចត់ ប្រកបដោយភាពសុក្រឹត ដោយបានចែកចេញជា ៣ដំណាក់កាល រួមមាន៖ ១. ការសម្រិតសម្រាំងលើគុណវុឌ្ឍិរបស់បេក្ខជន ២. វិញ្ញាសាសរសេរ (ចំណេះដឹងនិងបទពិសោធន៍ពាក់ព័ន្ធនឹងជំនាញច្បាប់ ការប្រើប្រាស់ភាសាខ្មែរលើការសង្ខេបខ្លឹមសារនិងទម្រង់ និងការសរសេរជាភាសាអង់គ្លេស ឬ/និងបារាំង) និង ៣. វិញ្ញាសារផ្ទាល់មាត់។

**គ.ក.ច.** បានផ្សព្វផ្សាយអំពីការជ្រើសរើសអ្នកជំនាញការផ្នែកច្បាប់ នាថ្ងៃទី២១ ខែតុលា ឆ្នាំ ២០២៤ មានបេក្ខជនដាក់ពាក្យសរុបចំនួន ១៧៣រូប ហើយបន្ទាប់ពីធ្វើការសម្រិតសម្រាំងយ៉ាងល្អិតល្អន់ដោយផ្តោតលើកម្រិតសញ្ញាបត្រ គួបផ្សំនឹងបទពិសោធន៍ការងារ បេក្ខជនចំនួន ១៥៥រូប ត្រូវបាន

ជ្រើសរើសឱ្យបន្តទៅវគ្គវិញ្ញាសាសរសេរ និងមានបេក្ខជនចំនួន ៣៣រូបប៉ុណ្ណោះដែលឈានដល់វគ្គវិញ្ញាសាផ្ទាល់មាត់ ដោយដំណាក់កាលលើកទី១ គណៈកម្មការប្រឡងសម្រេចជ្រើសរើសបេក្ខជនតែ ៨ រូបប៉ុណ្ណោះ នៃចំនួន ១៥រូប និងនៅក្នុងដំណាក់កាលលើកទី២ គណៈកម្មការប្រឡងសម្រេចជ្រើសរើសបេក្ខជនតែ ៥រូបប៉ុណ្ណោះនៃចំនួន ១៨រូប។

## ៣.៥. ការរៀបចំទីស្នាក់ការរបស់អគ្គលេខាធិការដ្ឋាន គ.ក.ច.

### ក. ការសិក្សាទំហំរបស់ទីស្នាក់ការ

ដោយផ្អែកតាមការសិក្សាលើទំហំការងារ និងតម្រូវការធនធានមនុស្សសម្រាប់បំពេញការងារនាពេលបច្ចុប្បន្ន និងអនាគតនៅក្នុងអគ្គលេខាធិការដ្ឋាន **គ.ក.ច.** មានតម្រូវការធនធានមនុស្សយ៉ាងតិច ៣២រូប ដែលចំនួននេះរួមបញ្ចូល អគ្គលេខាធិការ ១រូប អគ្គលេខាធិការរងចំនួន ២រូប ទីប្រឹក្សាចំនួន ២ រូប និងជំនួយការចំនួន ២រូប នាយកដ្ឋានគោលនយោបាយនិងផែនការចំនួន ១០រូប នាយកដ្ឋានប្រឹក្សាច្បាប់និងតាមដានការអនុវត្តច្បាប់ចំនួន ១០រូប នាយកដ្ឋានផ្សព្វផ្សាយ ទំនាក់ទំនងសាធារណៈ និងកិច្ចសហប្រតិបត្តិការចំនួន ៨រូប និងនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញកិច្ចចំនួន ៣រូប។ យោងទៅតាមចំនួនធនធានមនុស្សខាងលើ អ្នកសិក្សាប្លង់បានសិក្សាដោយព្រាងជាប្លង់ទីស្នាក់ការដែលជាលទ្ធផលទំហំត្រូវការគឺ ២៨០$m^2$ ឡើងទៅ។

### ខ. ការសិក្សាប្រៀបធៀបទីតាំងដែលល្អបំផុត

ដោយផ្អែកតាមតម្រូវការទំហំអគារដែលបានកំណត់ខាងលើ ក្រុមការងារបានធ្វើការសិក្សាទៅលើអគារដែលមានទីតាំងនៅជិតទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន ១៥ទីតាំង និងកំណត់យក ៦ទីតាំងដែលមានសក្តានុពលសម្រាប់ធ្វើជាទីស្នាក់ការបណ្តោះអាសន្នរបស់ អគ្គលេខាធិការដ្ឋាន **គ.ក.ច.** មកសិក្សាលម្អិតទៅលើលក្ខខណ្ឌបត់បែននៃកិច្ចសន្យាជួល តម្លៃអគ្គិសនី ទឹក ចំណាយលើសេវាផ្សេងៗ ដូចជាសេវាគ្រប់គ្រង ចំណតរថយន្ត ក៏ដូចជាថ្លៃសេវាអ៊ីនធឺណិត និងចំណាយក្នុងរយៈពេលមួយខែ និងមួយឆ្នាំទៅលើទីតាំងខាងលើនេះ។ ជាលទ្ធផលយើងបានសម្រេចជ្រើសរើសយកទីតាំងនៅ B&V Mansion មានទីតាំងនៅតំបន់ OCIC ជ្រោយចង្វារ ជាជម្រើសល្អជាងគេដោយផ្អែកទៅលើតម្លៃ និងភាពបត់បែននៃកិច្ចសន្យា ជាអគារថ្មីទើបនឹងសាងសង់រួចរាល់ពុំទាន់បានប្រើប្រាស់ មានចំណតគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ និងទីតាំងនៃអគារមានចម្ងាយជិតនឹងទីស្តីការគណៈរដ្ឋមន្ត្រី។

### គ. ការគូរប្លង់បឋម

បន្ទាប់ពីបានសិក្សាប្រៀបធៀប និងកំណត់យកទីតាំងអគាររួចមក អ្នកសិក្សាប្លង់បានគូសបាតប្លង់គោលដែលមានពីរជាន់ ដោយផ្អែកទៅតាមទម្រង់អគារ និងតម្រូវការបន្ទប់ទៅតាមចំនួនធនធានមនុស្សដែលនឹងត្រូវទៅបំពេញការងារប្រចាំថ្ងៃនៅទីស្នាក់ការរបស់អគ្គលេខាធិការដ្ឋាន **គ.ក.ច.**។

### ឃ. សម្ភារ គ្រឿងបរិក្ខារ ប្រព័ន្ធអគ្គិសនី និងបច្ចេកវិទ្យា

ដោយផ្អែកទៅតាមប្លង់គោលបឋមខាងលើ អ្នកគូរប្លង់បានពិគ្រោះយោបល់ និងសិក្សាលម្អិតទៅលើតម្រូវការសម្ភារ គ្រឿងបរិក្ខារ ប្រព័ន្ធអគ្គិសនី និងបច្ចេកវិទ្យាសម្រាប់រៀបចំ និងតម្លើងនៅទីតាំងស្នាក់ការរបស់អគ្គលេខាធិការដ្ឋាន **គ.ក.ច.**។

## ៣.៦. ការដឹកនាំ និងរៀបចំកិច្ចប្រជុំវឌ្ឍនភាពការងារ

### ក. កិច្ចប្រជុំផ្ទៃក្នុងលើកទី១

**ឯកឧត្តម លី ច័ន្ទតុលា** អនុប្រធាននិងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.** និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.** បានដឹកនាំកិច្ចប្រជុំ ដោយមានការចូលរួមពីអ្នកជំនាញការច្បាប់ ដើម្បីពិនិត្យ តាមដានវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពការងារប្រចាំខែមេសា និងប្រចាំត្រីមាសទី១ នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៥ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ នៅក្នុងនោះកិច្ចប្រជុំក៏បានពិភាក្សាលើសេចក្ដីព្រាងបង្កើតការិយាល័យចំណុះនាយកដ្ឋានរបស់អគ្គលេខាធិការដ្ឋាន **គ.ក.ច.** និងសេចក្ដីព្រាងទស្សនាទានដើម្បីរៀបចំវិបស្សនាស្ដីពីអត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជាផងដែរ។

### ខ. កិច្ចប្រជុំផ្ទៃក្នុងលើកទី២

**ឯកឧត្តម លី ច័ន្ទតុលា** អនុប្រធាននិងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.** និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.** បានដឹកនាំកិច្ចប្រជុំ ដោយមានការចូលរួមពីអ្នកជំនាញការច្បាប់ ដើម្បីពិនិត្យ និងពិភាក្សាលើវឌ្ឍនភាពនៃការរៀបចំឯកសារផែនការសកម្មភាពឆ្នាំ ២០២៥ - ២០២៦ នាថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៥ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។

### គ. កិច្ចប្រជុំផ្ទៃក្នុងលើកទី៣

**ឯកឧត្តម លី ច័ន្ទតុលា** អនុប្រធាននិងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.** និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន **គ.ក.ច.** បានដឹកនាំកិច្ចប្រជុំ ដោយមានការចូលរួមពីអ្នកជំនាញការច្បាប់ ដើម្បីពិភាក្សាលើវឌ្ឍនភាពការងារចំពោះមុខរបស់អគ្គលេខាធិការដ្ឋាន **គ.ក.ច.** និងការត្រៀមរៀបចំបង្កើតក្រុមការងារកែទម្រង់ច្បាប់ក្នុងក្រសួង ស្ថាប័ន នាថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៥ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ នៅក្នុងនោះផងដែរ ឯកឧត្តមអគ្គលេខាធិការក៏បានបែងចែកការងារជូនដល់អ្នកជំនាញការច្បាប់ **គ.ក.ច.** ដែលទើបចូលបម្រើការងារថ្មីផងដែរ។

## ៣.៧. កម្មវិធីផ្សេងៗ

### ក. ការចូលរួមកម្មវិធីទិវាប្រចាំឆ្នាំរបស់យន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល (យ.ស.ក.)

**ឯកឧត្តម លី ច័ន្ទតុលា** អនុប្រធាននិងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.** និង **ឯកឧត្តម ស៊ា ម៉ៅ** អនុប្រធានប្រចាំការ **គ.ក.ច.** បានអញ្ជើញជាគណៈអធិបតីនៃកម្មវិធី អមដោយ **ឯកឧត្តម ប៉ែន ម៉ុនឈា** អគ្គលេខាធិការរង **គ.ក.ច.** និងជំនាញការច្បាប់នៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.** ពីថ្ងៃទី២៦ ដល់២៧ ខែមីនា ឆ្នាំ២០២៥ នៅសណ្ឋាគារសុខាសៀមរាប ខេត្តសៀមរាប។ ក្នុងគោលបំណងកំណត់ចេញជាសកម្មភាពអាទិភាព និងប្រទាក់ក្រឡាគ្នារវាងកម្មវិធីកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល និងការធ្វើបច្ចុប្បន្នកម្មចក្ខុវិស័យនិងយុទ្ធសាស្ត្ររបស់យន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះ នៃរាជរដ្ឋាភិបាល (**យ.ស.ក.**) និងមានការចូលរួមពីតំណាងអគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការកែទម្រង់ទាំង ៥ និងអង្គភាពជំនាញពាក់ព័ន្ធនៃក្រសួងដឹកនាំការងារកែទម្រង់ទាំង ៥។

### ខ. ការចូលរួមសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៤ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០២៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.** បានចូលរួមសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៤ និងលើកទិសដៅការងារសម្រាប់ឆ្នាំ២០២៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រីក្រោមអធីបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី។

### គ. ការចូលរួមដឹកនាំកិច្ចប្រជុំប្តូរវេន ស្តីពីយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល (យ.ស.ក.) ប្រចាំត្រីមាសទី១

**ឯកឧត្តម លី ច័ន្ទតុលា** អនុប្រធាននិងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.** បានអញ្ជើញជាគណៈអធិបតី អមដោយ **ឯកឧត្តម ប៉ែន ម៉ុនឈា** អគ្គលេខាធិការរង **គ.ក.ច.** និង **ឯកឧត្តម សោម គន្ធា** អគ្គលេខាធិការរង **គ.ក.ច.** និងអ្នកជំនាញការច្បាប់នៃ **គ.ក.ច.** នាថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៥ នៅសណ្ឋាគារ Raffles Le Royal រាជធានីភ្នំពេញ ក្នុងគោលបំណងកំណត់ចេញជាសកម្មភាពអាទិភាពនិងប្រទាក់ក្រឡាគ្នារវាងកម្មវិធីកែទម្រង់គន្លឹះរបស់រាជរដ្ឋាភិបាល និងការធ្វើបច្ចុប្បន្នកម្មចក្ខុវិស័យនិងយុទ្ធសាស្ត្ររបស់ **យ.ស.ក.**។ កិច្ចប្រជុំប្តូរវេនប្រចាំត្រីមាសទី១ មាន

ការចូលរួមពីតំណាងអគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការកែទម្រង់ទាំង ៥ និងអង្គភាពជំនាញពាក់ព័ន្ធនៃក្រសួងដឹកនាំការងារកែទម្រង់ទាំង ៥។

### ឃ. ការចូលរួមដឹកនាំកិច្ចប្រជុំជំនាញបច្ចេកទេស ដើម្បីពិនិត្យ និងពិភាក្សាបន្តលើ សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែក និងដីចំណីផ្លូវដែក

**ឯកឧត្តម លី ច័ន្ទតុលា** អនុប្រធាននិងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.** បានដឹកនាំកិច្ចប្រជុំជំនាញបច្ចេកទេស ដើម្បីពិនិត្យ និងពិភាក្សាបន្តលើ សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងផ្លូវឆ្លងកាត់ផ្លូវដែក និងដីចំណីផ្លូវដែក ដោយមានការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ តំណាង **គ.ក.ច.** ក្រុមប្រឹក្សាអ្នកច្បាប់ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាជាតិភាសាខ្មែរ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួង ស្ថាប័នពាក់ព័ន្ធ នាថ្ងៃទី៧ ខែឧសភា ឆ្នាំ ២០២៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី។

### ង. ការចូលរួមកិច្ចប្រជុំចង្អៀតដើម្បីពិនិត្យ ពិភាក្សា និងកែសម្រួលលើ ១. សេចក្តីព្រាងកិច្ចព្រមព្រៀងរក្សាការសម្ងាត់រវាងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) និង Rusatom Overseas Joint Stock Company (RAOS) និង ២. ផែនទីបង្ហាញផ្លូវរវាង ក.ជ.អ.ច. និងសាជីវកម្មថាមពលបរមាណូរដ្ឋសហព័ន្ធរុស្ស៊ី (Rosatom)

**ឯកឧត្តម លី ច័ន្ទតុលា** បានចាត់អ្នកជំនាញការច្បាប់ **គ.ក.ច.** ចូលរួមកិច្ចប្រជុំចង្អៀត ដើម្បីពិនិត្យ ពិភាក្សា និងកែសម្រួលលើ ១. សេចក្តីព្រាងកិច្ចព្រមព្រៀងរក្សាការសម្ងាត់រវាងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) និង Rusatom Overseas Joint Stock Company (RAOS) និង ២. ផែនទីបង្ហាញផ្លូវរវាង ក.ជ.អ.ច. និងសាជីវកម្មថាមពលបរមាណូរដ្ឋសហព័ន្ធរុស្ស៊ី (Rosatom) ក្រោមអធិបតីភាព **ឯកឧត្តម សួន សុភ័ណ្ឌា** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី។

### ច. ការចូលរួមកម្មវិធីចែករំលែកចំណេះដឹង និងបទពិសោធន៍ស្តីពីក្រមភាវូបនីយកម្មនិងបច្ចេកវិទ្យា

**ឯកឧត្តម លី ច័ន្ទតុលា** បានចាត់អ្នកជំនាញការច្បាប់ **គ.ក.ច.** ចូលរួមកម្មវិធីចែករំលែកចំណេះដឹង និងបទពិសោធន៍ស្តីពីក្រមភាវូបនីយកម្មនិងបច្ចេកវិទ្យា ដែលមានវត្តមានវាគ្មិនកិត្តិយស លោកស្រី Elisabeth CATTA ចៅក្រម និងជាសមាជិកគណៈកម្មការជាន់ខ្ពស់ក្រមនីយកម្មបារាំង និង

ដែលធ្លាប់ជាសមាជិកស្ថាបនិកនៃក្រុមការងាររៀបចំសេចក្តីព្រាងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងលោក Alexendre Delliaux អ្នកវិទ្យាសាស្ត្រកុំព្យូទ័រ និងជាអ្នកជំនាញផ្នែកទិន្នន័យឌីជីថល ក្រោមអធិបតីភាព **ឯកឧត្តម ហៅល ចំរើន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនិងជាអនុប្រធានប្រចាំការក្រុមប្រឹក្សានីតិកម្ម នាថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៥ នៅសណ្ឋាគារ រ៉ាសហ្វលឡឺរ៉ូយ៉ាល់ភ្នំពេញ។

### ឆ. រៀបចំសិក្ខាសាលាស្តីពីការកែទម្រង់ច្បាប់នៅព្រះរាជាណាចក្រកម្ពុជា

